អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

# សេចក្ដីប្រកាសព័ត៌មាន

## អ.វ.ត.ក. សហការរៀបចំការប្រកួតសវនាការប្រឌិត John H. Jackson លើកទី២២ សម្រាប់ថ្នាក់តំបន់អាស៊ីប៉ូពាំ និង អូសេអានី ស្ដីពីនីតិពាណិជ្ជកម្មអន្តរជាតិ

**ភ្នំពេញ ប្រទេសកម្ពុជា** - អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ បានសហការរៀបចំសវនាការប្រឌិត John H. Jackson លើកទី២២ សម្រាប់ថ្នាក់តំបន់អាស៊ីប៉ូពាំនិងអូសេអានី ស្ដីពីនីតិពាណិជ្ជកម្មអន្តរជាតិ ក្រោមកិច្ចសហប្រតិបត្តិការមួយសកលវិទ្យាល័យជាតិគ្រប់គ្រង និង សមាគមន៍និស្សិតច្បាប់អឺរ៉ុប ដោយគាំទ្រផ្នែកបច្ចេកទេសពីអង្គការពាណិជ្ជកម្មពិភពលោក (WTO)។

ក្រុមចំនួន៩ មកពី កម្ពុជា ចិន ឥណ្ឌូនេស៊ី សិង្ហបុរី តៃវ៉ាន់ និង វៀតណាម បានចូលរួមក្នុងការប្រកួតជុំតំបន់អាស៊ីប៉ូពាំ និង អូសេអានី ដែលធ្វើឡើងនៅប្រទេសកម្ពុជា ចាប់ពីថ្ងៃទី៩-១៣ ខែមីនា ឆ្នាំ២០២៤។ ក្រុមចំនួន៤ បានត្រូវជ្រើសរើសទៅប្រកួតវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រ និង វគ្គផ្ដាច់ព្រ័ត្រ ដែលបានរៀបចំនៅបន្ទប់សវនាការ នៃមជ្ឈមណ្ឌលធនធាន អ.វ.ត.ក.។ ក្រុមចំនួន២ ដែលបានឈ្នះលេខ១ និង លេខ២ សម្រាប់ថ្នាក់តំបន់អាស៊ីប៉ូពាំនិងអូសេអានី នឹងឈានទៅវគ្គបន្ត ដើម្បីចូលរួមការប្រកួតជុំអន្តរជាតិ ដែលធ្វើឡើងនៅទីស្នាក់ការរបស់អង្គការពាណិជ្ជកម្មពិភពលោក ក្នុងទីក្រុងហ្សឺណែវ ប្រទេសស្វីស។

ឯកឧត្តម **ក្រាញ់ តូនី** ប្រធានរដ្ឋបាលស្ដីទី អ.វ.ត.ក. មានប្រសាសន៍ថា៖ «ការធ្វើជាម្ចាស់ផ្ទះរៀបចំការសវនាការប្រឌិត John H. Jackson នៅថ្ងៃនេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ នៅពេលដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះការប្រកួតសវនាការប្រឌិតនេះ ថ្នាក់តំបន់ ជាលើកដំបូងរបស់ខ្លួន។ អ.វ.ត.ក. មានសេចក្ដីសោមនស្សរីករាយដែលបានទទួលសិស្សានុសិស្សផ្នែកច្បាប់ និង គ្រូបង្វឹកទាំងរបស់ពួកគេមកទស្សនា និង ចូលរួមការប្រកួតនេះ ក្នុងវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រ និង ជុំផ្ដាច់ព្រ័ត្រ នៅបន្ទប់សវនាការរបស់ អ.វ.ត.ក. នៅថ្ងៃនេះ។ អ.វ.ត.ក. ចូលរួមអបអរសាទរដល់សិស្សានុសិស្សទាំងអស់ ចំពោះការខិតខំប្រឹងប្រែងរបស់ពួកគេ តាមរយៈការប្រកួតនេះ ហើយ អ.វ.ត.ក. នឹងគាំទ្រយ៉ាងសកម្មនូវគំនិតផ្ដួចផ្ដើមបែបនេះ នៅក្នុងដំណាក់កាលមុខងារសេសសល់របស់ខ្លួន»។

លោក **Shashank Kumar** អ្នកតំណាងអង្គការពាណិជ្ជកម្មពិភពលោក បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អ.វ.ត.ក. សម្រាប់ភាពជាដៃគូដ៏អស្ចារ្យ ក្នុងការសហការរៀបចំការប្រកួតសវនាការប្រឌិតនេះ។ លោកបានបន្ថែមថា៖ «ខ្ញុំពិតជាអរគុណដល់ អ.វ.ត.ក. ព្រោះនេះ គឺជាកិត្តិយសណាស់ ដែលបានរៀបចំឡើងនៅទីនេះ នៅក្នុងបន្ទប់សវនាការរបស់ អ.វ.ត.ក.។ អ.វ.ត.ក. គឺជាស្ថាប័នដ៏អស្ចារ្យមួយ ហើយការងារប្រភេទនេះ គឺពិតជាគួរឱ្យចាប់អារម្មណ៍»។

លោក **Maciej Lodzinski** អ្នកតំណាងសមាគមន៍និស្សិតច្បាប់អឺរ៉ុប មានប្រសាសន៍ថា៖ «យើងពិតជារីករាយដែលបានរៀបចំការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ និង វគ្គផ្តាច់ព្រ័ត្រ នៃការប្រកួត ជុំតំបន់អាស៊ីប៉ូស៊ីហ្វិកនិងអូសេអានី ដែលរៀបចំឡើងនៅ អ.វ.ត.ក. និង បន្ទប់សវនាការរបស់ អ.វ.ត.ក.។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អ.វ.ត.ក. ដែលបានធ្វើការលើគម្រោងនេះជាមួយពួកយើង»។

គួររំលឹកថា កាលពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០២៤ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានសហការរៀបចំការប្រកួតជុំចុងក្រោយ នៃការប្រកួតសវនាការប្រឌិត «ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌» ជាមួយវិទ្យាស្ថាន Raoul Wallenberg (RWI) និងមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនីតិមនុស្សធម៌អន្តរជាតិ (CSHL)៕

###

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**
លោក **គុណ ចិន្តា**
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន ផ្នែកកិច្ចការសាធារណៈ
លេខទូរស័ព្ទទំនាក់ទំនង៖ +៨៥៥ (0)១២ ៣៣៦ ០៩៧
អ៊ីម៉ែល៖ kun.chenda@eccc.gov.kh